ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ០៤២/២០ - យ៉ាំង ដុង ១ ខូអិលធីឌី
កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២០

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ យូ សួនទី
អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ អន ណន
ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ ប៉ែន ប៊ុនឈា

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ **ក្រុមហ៊ុន យ៉ាំង ដុង ១ ខូអិលធីឌី**
អាសយដ្ឋាន ៖ ភូមិក្បាលដំរី សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ
ទូរស័ព្ទ ៖ ០៧៨ ៤៤៦ ៩៤៣ ទូរសារ ៖ គ្មាន
តំណាងភាគីនិយោជកចូលរួមសវនាការ៖ អវត្តមាន

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖ **ភាគីតំណាងកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន យ៉ាំង ដុង ១ ខូអិលធីឌី**
អាសយដ្ឋាន ៖ ភូមិក្បាលដំរី សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ
ទូរស័ព្ទ ៖ ០១២៤៣ ៤៤ ១៦ ទូរសារ ៖ គ្មាន
តំណាងភាគីកម្មករនិយោជិតចូលរួមសវនាការ៖

១- លោកស្រី ឈាង ធីតា មន្ត្រីសហជីពស្មារតីកម្មករខ្មែរ
២- លោក ចាន់ រុំ មន្ត្រីសហជីពស្មារតីកម្មករខ្មែរ
៣- លោកស្រី វង់ ស៊ីនួន ហិរញ្ញិកសហជីព
៤- លោកស្រី យឹម សុផល កម្មករនិយោជិត

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- ស្នើសុំឱ្យក្រុមហ៊ុនសងរំលឹកប្រាក់ឈ្នួលជូនចំពោះកម្មការិនីដែលបានសម្រាលបុត្រួច(លុយ៥០%=៣ខែ) និងលុយ ប.ស.ស ដែលក្រុមហ៊ុនមិនទាន់ផ្តល់ជូន ដោយឡែកភាគីនិយោជកបានបញ្ជាក់ថា ក្រុមហ៊ុនពុំមានលទ្ធភាពផ្តល់ជូនតាមការស្នើសុំនោះទេ។

២- សូមឱ្យក្រុមហ៊ុនទូទាត់លុយជូនកម្មករ(កម្មករអណ្តែត) ដែលក្រុមហ៊ុនបានឱ្យជាលុយរំសាយក្នុងមួយខែ ចំនួន ២០$(ម្លៃដុល្លារអាមេរិក) ចំនួន ០២ខែ គឺខែមិថុនា និងខែកក្កដា ឆ្នាំ២០១៩ ដោយឡែកភាគីនិយោជកពុំមានលទ្ធភាពផ្តល់ជូនតាមការស្នើសុំដែលមានកម្មករចំនួន ២០នាក់ នោះទេ។

៣- ស្នើសុំឱ្យក្រុមហ៊ុនបង់លុយជូន ប.ស.ស ឱ្យបានគ្រប់ចំនួន ដើម្បីឱ្យកម្មករនិយោជិតបានប្រើប្រាស់សេវា ប.ស.ស នេះ ព្រោះជាងមួយឆ្នាំហើយ បងប្អូនកម្មករនិយោជិតគ្មានសេវានេះប្រើប្រាស់នោះទេ ដោយឡែកភាគីនិយោជកបានបញ្ជាក់ថា ពុំមានលទ្ធភាពបង់ជូន ប.ស.ស នោះទេ។

៤- ស្នើសុំឱ្យក្រុមហ៊ុនទូទាត់រំលឹកប្រាក់ភាគទានចំនួន ០៣ខែ ចាប់ពីខែមេសា ដល់ខែមិថុនា ឆ្នាំ២០២០ ជូនសហជីពស្មារតីកម្មករខ្មែរប្រចាំក្រុមហ៊ុន យាំង ដុង ១ ដោយឡែកភាគីនិយោជកពុំមានលទ្ធភាពទូទាត់រំលឹកប្រាក់ភាគទានបងប្អូនកម្មករនិយោជិត ជូនទៅសហជីពស្មារតីកម្មករខ្មែរនោះទេ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៨៥/២០ ក.ប/ប្រ.ក.វ.ក ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០ (អាណត្តិទី១៨)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែ ការផ្សះផ្សានោះភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន យាំង ដុង ១ ខូអិលធីឌី លេខ ៦៦៤ ក.ប/អក/វក ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០២០ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០២០។

## សវនាការ និង សង្ខេបនីតិវិធី

ទីកន្លែងសវនាការ ៖ ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

កាលបរិច្ឆេទសវនាការ ៖ ថ្ងៃចន្ទ ១៥រោច ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២០។

បញ្ជានីតិវិធី៖

នៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២០ នាយកដ្ឋានវិវាទការងារ បានទទួលពាក្យបណ្តឹងរបស់កម្មករនិយោជិតនៃក្រុមហ៊ុន យ៉ាំង ដុង ១ ខូអិលធីឌី ស្តីពីការទាមទារឱ្យក្រុមហ៊ុនដោះស្រាយលក្ខខណ្ឌការងារចំនួន ៧ ចំណុច។ បន្ទាប់ពីទទួលពាក្យបណ្តឹងនេះមក នាយកដ្ឋានវិវាទការងារ បានចាត់មន្ត្រីជំនាញឱ្យដោះស្រាយវិវាទការងារនេះ ទៅតាមនីតិវិធីច្បាប់នៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២០ ដោយទទួលបានលទ្ធផលសះជានឹងគ្នាចំនួន ៣ចំណុច។ ចំណុចមិនសះជាចំនួន ៤ ចំណុច ដែលនៅសល់ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០២០ តាមរយៈរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន យ៉ាំង ដុង ១ ខូអិលធីឌី លេខ ៦៦៤ ក.ប/អក/វក ចុះថ្ងៃទី២ ខែកក្កដា ឆ្នាំ២០២០។

បន្ទាប់ពីបានទទួលសំណុំរឿងនេះ ក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើងនៅថ្ងៃទី៧ ខែកក្កដា ឆ្នាំ ២០២០។ លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល បានអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងផ្សះផ្សា នៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២០ វេលាម៉ោង ២ និង ០០ នាទី រសៀល។ យ៉ាងណាមិញ នៅថ្ងៃសវនាការ ភាគីកម្មករនិយោជិត និងតំណាងរបស់ភាគីនិយោជក បានស្នើសុំលើកពេលសវនាការទៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២០ ពីព្រោះនិយោជករវល់ មិនអាចចូលរួមសវនាការបាន។ តាមរយៈការស្នើសុំពីភាគីទាំងពីរ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានសម្រេចលើកពេលសវនាការពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២០ វេលាម៉ោង ២ និង ០០ នាទី រសៀល ទៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២០ វេលាម៉ោង ២ និង ០០ នាទី រសៀល។

នៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២០ វេលាម៉ោង ៣ និង ១ នាទី រសៀល លេខាធិការដ្ឋាននៃក្រុមប្រឹក្សា-អាជ្ញាកណ្តាលបានចេញលិខិតអញ្ជើញភាគី និងទាក់ទងភាគីតាមរយៈទូរសព្ទ និងអ៊ីម៉ែល ដើម្បីឱ្យមកចូលរួមក្នុងសវនាការអាជ្ញាកណ្តាល តាមរយៈលិខិតអញ្ជើញលេខ ១៤៤ កប/អក/វក/លកអ. ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០២០ ដោយមានភ្ជាប់ជាមួយនូវព័ត៌មានច្បាស់លាស់អំពីកាលបរិច្ឆេទនៃសវនាការ ទីកន្លែងនៃសវនាការ ព្រមទាំងលេខទូរសព្ទ/ទូរសារ សម្រាប់ទំនាក់ទំនងមកក្រុមប្រឹក្សាអាជ្ញាកណ្តាលផងដែរ។ តំណាងរបស់ភាគីនិយោជក បានប្រាប់ថានឹងជូនដំណឹង និងលិខិតអញ្ជើញនេះទៅឱ្យនិយោជក។

លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល បានអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងផ្សះផ្សា នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២០ វេលាម៉ោង ២ និង ០០ នាទី រសៀល។

ដោយឡែក នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២០ វេលាពេលព្រឹក មន្ត្រីលេខាធិការដ្ឋាននៃក្រុមប្រឹក្សា-អាជ្ញាកណ្តាល បានទូរសព្ទទាក់ទងទៅតំណាងភាគីនិយោជក ដើម្បីបញ្ជាក់អំពីការចូលរួមសវនាការរបស់ភាគី ប៉ុន្តែតំណាងភាគីនិយោជកបានបញ្ជាក់ថា និយោជកមិននៅក្រុមហ៊ុនទេ ហើយគ្មានអ្នកអាចចេញលិខិតផ្ទេរសិទ្ធិឱ្យប្រធានផ្នែករដ្ឋបាល តំណាងឱ្យនិយោជកចូលរួមសវនាការបាននោះទេ។ ដូចនេះ ប្រធានផ្នែករដ្ឋបាលពុំមានសិទ្ធិតំណាងឱ្យនិយោជក ចូលរួមសវនាការនោះទេ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមស្វះរកនូវអង្គហេតុផ្សេងៗ ដែលទាក់ទងទៅនឹងចំណុចវិវាទមិនសះជាចំនួន ៤ ចំណុចនេះ ហើយភាគីកម្មករនិយោជិតសម្រេចដកការទាមទារចំនួន ១ ចំណុច ចេញពីសំណុំរឿងនេះ គឺចំណុចវិវាទទី៤។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងពិចារណាចំណុចវិវាទដែលនៅសល់ចំនួន ៣ ចំណុច គឺចំណុចវិវាទទី១, ចំណុចវិវាទទី២ និងចំណុចវិវាទទី៣។

នៅក្នុងសំណុំរឿងនេះ ប្រភេទសេចក្តីបង្គាប់អាជ្ញាកណ្តាលគឺជាសេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច។

នៅថ្ងៃសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានកំណត់ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២០ ជាថ្ងៃផុតកំណត់ផ្តល់ឯកសារភស្តុតាង និងថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២០ ជាថ្ងៃផុតកំណត់ជំទាស់ឯកសារភស្តុតាង។

កាលបរិច្ឆេទនៃការចេញសេចក្តីបង្គាប់អាជ្ញាកណ្តាល គឺនៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២០។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងដោះស្រាយលើចំណុចវិវាទខាងលើនេះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម ៖

**ភស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

**ឯកសារ វត្ថុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

ក- ឯកសារបានទទួលពីភាគីនិយោជក ៖ គ្មាន

ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖

១- វិញ្ញាបនបត្រចុះបញ្ជីអង្គការវិជ្ជាជីវៈសហជីពស្មារតីកម្មករខ្មែរក្រុមហ៊ុន យ៉ាំង ដុង ១ នៃក្រុមហ៊ុន យ៉ាំង ដុង ១ ខូអិលធីឌី លេខ ២៩៤ ក.ប/វ.ប.វ.ក ចុះថ្ងៃសុក្រ ៩រោច ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៨។

២- លិខិតលេខ ១៦៤ កប/វក ចុះថ្ងៃសុក្រ ៩រោច ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៨ របស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានបញ្ជាក់ថា សហជីពស្មារតីកម្មករខ្មែរក្រុមហ៊ុន យ៉ាំង ដុង ១ នៃក្រុមហ៊ុន យ៉ាំង ដុង ១ ខូអិលធីឌី ជាអង្គការវិជ្ជាជីវៈមួយ ត្រូវបានចុះបញ្ជីនៅនាយកដ្ឋានវិវាទការងារ និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ ចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ។

៣- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន យ៉ាំង ដុង ១ ខូអិលធីឌី ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២០។

៤- ពាក្យបណ្តឹង ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២០ របស់តំណាងកម្មករនិយោជិតនៃក្រុមហ៊ុន យ៉ាំង ដុង ១ ខូអិលធីឌី គោរពជូន ប្រធាននាយកដ្ឋានវិវាទការងារ ស្តីពីសុំប្តឹងថៅកែក្រុមហ៊ុន យ៉ាំង ដុង ១ ខូអិលធីឌី ដែលមិនគោរពច្បាប់ស្តីពីការងារ។

៥- លិខិតចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២០ របស់តំណាងកម្មករនិយោជិតនៃក្រុមហ៊ុន យ៉ាំង ដុង ១ ខូអិលធីឌី គោរពជូនក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសំណើសុំពន្យារពេលសវនាការសំណុំរឿងលេខ ០៤២/២០ ក្រុមហ៊ុន យ៉ាំង ដុង ១។

៦- លិខិតលេខ ២៦៤ កប/អក/វក/លកអ. ចុះថ្ងៃ ចុះថ្ងៃពុធ ១០រោច ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២០ ស្តីពីការអញ្ជើញភាគីកម្មករនិយោជិតនៃក្រុមហ៊ុន យ៉ាំង ដុង ១ ខូអិលធីឌី ចូលរួមសវនាការ។

៧- បញ្ជីឈ្មោះអ្នកបណ្តែតលុយចាប់ពីខែមិថុនា ដល់ខែកក្កដា ឆ្នាំ២០១៩។

៨- បញ្ជីឈ្មោះអ្នកសម្រាលកូនមិនទាន់បានលុយ៥០% ពីរោងចក្រ និង ៧០% ពី ប.ស.ស.។

គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន យ៉ាំង ដុង ១ ខូអិលធីឌី លេខ ៦៦៤ ក.ប/អក/វក ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០២០។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន យ៉ាំង ដុង ១ ខូអិលធីឌី ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២០។

៣- លិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន យ៉ាំង ដុង ១ ខូអិលធីឌី លេខ ០២៦/២០ កប/អក/វក/ករក៤ ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២០ របស់នាយកដ្ឋានវិវាទការងារ។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១- លិខិតលេខ ២៤៨ កប/អក/វក/លកអ. ចុះថ្ងៃចន្ទ ១រោច ខែអាសាឍ ឆ្នាំជូត ទោស័ក ព. ស ២៥៦៤ ត្រូវនឹងថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២០ របស់លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ជម្រាបមកលោកនាយកក្រុមហ៊ុន យ៉ាំង ដុង ១ ខូអិលធីឌី ស្តីពីការជ្រើសរើសអាជ្ញាកណ្តាល។

២- កំណត់ហេតុស្តីពីការចាប់ឆ្នោតជ្រើសរើសអាជ្ញាកណ្តាលពីបញ្ជីឈ្មោះអាជ្ញាកណ្តាល ស្នើដោយសមាគមនិយោជក ចុះថ្ងៃអង្គារ ២រោច ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០២០។

៣- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ២៥៣ កប/អក/វក/លកអ. ចុះ ថ្ងៃពុធ ៣រោច ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០២០។

៤- លិខិតអញ្ជើញភាគីកម្មករនិយោជិត ចូលរួមសវនាការ លេខ ២៥៤ កប/អក/វក/លកអ. ចុះ ថ្ងៃពុធ ៣រោច ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០២០។

៥- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ២៦៣ កប/អក/វក/លកអ. ចុះ ថ្ងៃពុធ ១០រោច ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២០។

៦- លិខិតអញ្ជើញភាគីកម្មករនិយោជិត ចូលរួមសវនាការ លេខ ២៦៤ កប/អក/វក/លកអ. ចុះ ថ្ងៃពុធ ១០រោច ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២០។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖

- ក្រុមហ៊ុននេះមានសកម្មភាពចម្បងផ្នែកកាត់ដេរសម្លៀកបំពាក់ និងមានជួលកម្មករនិយោជិតសរុបចំនួន ១៨០នាក់។ *(យោងតាមរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន យ៉ាំង ដុង ១ ខូអិលធីឌី)*
- លិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន យ៉ាំង ដុង ១ ខូអិលធីឌី លេខ ០២៦/២០កប/អក/វក/ករក៤ ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២០ របស់នាយកដ្ឋានវិវាទការងារ ដែលមានឈ្មោះកម្មករនិយោជិតចំនួន ៥ នាក់ ដូចជា ៖ លោកស្រី វ៉ង់ ស៊ីនួន

លោក ខុត វ៉ិត, លោក ម៉េង ហួត, លោក យៃម ចន្ទា, លោក ទូច ភា និង លោក ទុយ វដ្ឋា ជាអ្នកតំណាងកម្មករនិយោជិត។

- យោងតាមពាក្យបណ្តឹងរបស់ភាគីកម្មករនិយោជិត ដែលប្តឹងនិយោជកមិនបានគោរពច្បាប់ស្តីពីការងារ ចុះថ្ងៃ១ ខែកក្កដា ឆ្នាំ២០២០ កម្មករនិយោជិតដែលផ្តិតមេដៃជាដើមបណ្តឹងទាមទារមានចំនួន ១៨៤ នាក់។

ចំណុចវិវាទទី ១ ៖ ស្នើសុំឱ្យក្រុមហ៊ុនសងរំលឹកប្រាក់ឈ្នួលឈប់សម្រាកលំហែមាតុភាពជូនចំពោះកម្មការិនីដែលបានសម្រាលបុត្ររួច (ប្រាក់ឈ្នួល ៥០% រយៈពេល ៣ ខែ) និងប្រាក់ ប.ស.ស. ដែលក្រុមហ៊ុនមិនទាន់ទូទាត់ជូន

- ភាគីកម្មករនិយោជិតបញ្ជាក់ការទាមទារ ឱ្យនិយោជកសងរំលឹកប្រាក់ឈ្នួលឈប់សម្រាកលំហែមាតុភាពចំនួន ៥០ ភាគរយ រយៈពេល ៣ ខែ និងប្រាក់បំណាច់មាតុភាព (ប្រាក់បំណាច់ប្រចាំថ្ងៃចំនួន ៧០ ភាគរយនៃប្រាក់ឈ្នួលមធ្យមជាប់ភាគទាន ប.ស.ស. ប្រចាំថ្ងៃរបស់សាមីជនសម្រាប់រយៈពេល ៩០ ថ្ងៃ នៃការឈប់សម្រាកមុន និងក្រោយសម្រាលកូន) ជូនកម្មករនិយោជិតដែលបានឈប់សម្រាកលំហែមាតុភាពរួច។
- ភាគីកម្មករនិយោជិតបានបញ្ជាក់មូលហេតុនៃការទាមទារថា ៖
  - កម្មករនិយោជិតដែលមិនទាន់ទទួលបានប្រាក់ឈ្នួលឈប់សម្រាកមាតុភាពចំនួន ៥០ ភាគរយ ពីនិយោជក និងប្រាក់បំណាច់មាតុភាព មានចំនួនប្រមាណ ២០ នាក់។ ពួកគាត់បានធ្វើការលើសពីពីរឆ្នាំ។
  - កាលពីឆ្នាំ ២០១៨ និយោជកធ្លាប់ទូទាត់ប្រាក់ឈ្នួលឈប់សម្រាកលំហែមាតុភាពជូនកម្មករនិយោជិត តែចាប់ពីឆ្នាំ២០១៩ ហូតមកដល់ពេលបច្ចុប្បន្ន និយោជកមិនបានទូទាត់ជូនកម្មករនិយោជិតនោះទេ។
  - និយោជកត្រូវតែបង់ប្រាក់ភាគទានជូន ប.ស.ស. សម្រាប់កម្មករនិយោជិត ពីព្រោះនៅពេលដែលនិយោជកមិនបានបង់ប្រាក់ភាគទានជូន ប.ស.ស. កម្មករនិយោជិតមិនអាចប្រើប្រាស់សេវារបស់ ប.ស.ស. នៅមន្ទីរពេទ្យបាននោះទេ។
  - កាលពីមុន និយោជកបង់ប្រាក់ភាគទានជូន ប.ស.ស. សម្រាប់តែកម្មករនិយោជិតដែលជិតដល់ថ្ងៃសម្រាលបុត្រតែប៉ុណ្ណោះ ចំណែកឯសម្រាប់កម្មករនិយោជិតផ្សេងទៀត និយោជកមិនបានបង់ប្រាក់ភាគទានជូន ប.ស.ស. នោះទេ ពីព្រោះនៅពេលដែលកម្មករនិយោជិតទៅមន្ទីរពេទ្យជាដៃគូរបស់ ប.ស.ស. គ្រូពេទ្យប្រាប់ថា និយោជកមិនបានបង់ប្រាក់ភាគទាននោះទេ ដូចនេះ ពួកគាត់មិនអាចទូទាត់ថ្លៃសេវាតាមបណ្ណ ប.ស.ស. បាននោះទេ។
- ភាគីកម្មករនិយោជិតបានដាក់បញ្ជីឈ្មោះកម្មករនិយោជិតដែលទាមទារប្រាក់ឈ្នួលសម្រាកលំហែមាតុភាព និងប្រាក់បំណាច់មាតុភាព មានកម្មករនិយោជិតសរុបចំនួន ៨នាក់ មានឈ្មោះ៖ ស៊ិន សម្ផស្ស អត្តលេខ LC.096, ជុំ សុខលាប អត្តលេខ Off.005, ឡេង ចាន់ណា អត្តលេខ Off.006, យ៉ែម ចាន់ជា អត្តលេខ L4.049, សយ ធារី អត្តលេខ L3.106, ថេង សុខឡេង អត្តលេខ L5.001, ផៃ សារិន អត្តលេខ L6.001 និង រឿន ធារី អត្តលេខ L4.007។

THE ARBITRATION COUNCIL

ចំណុចវិវាទទី ២ ៖ សូមឱ្យក្រុមហ៊ុនទូទាត់ប្រាក់ជូនកម្មករនិយោជិត (កម្មករបណ្តែត) ដែលក្រុមហ៊ុនបានសន្យាឱ្យប្រាក់សោយក្នុងមួយខែចំនួន ២០$ (ម្ភៃដុល្លាអាមេរិក) ចំនួន ០២ ខែ គឺខែមិថុនា និងខែកក្កដា ឆ្នាំ២០១៩

- ភាគីកម្មករនិយោជិតបញ្ជាក់ការទាមទារ ឱ្យនិយោជកផ្តល់ប្រាក់រង់ចាំការងារចំនួន ២០ ដុល្លារអាមេរិក ក្នុងមួយខែ សម្រាប់ខែមិថុនា និងខែកក្កដា ឆ្នាំ២០២០ តាមការសន្យាដោយផ្ទាល់មាត់របស់និយោជកជូនកម្មករនិយោជិតម្តងម្កាលចំនួន ២០ នាក់។
- ភាគីកម្មករនិយោជិតបានបញ្ជាក់ថា ៖
    - និយោជកបានសន្យាថានឹងផ្តល់ប្រាក់រង់ចាំការងារចំនួន ២០ ដុល្លារអាមេរិក ក្នុងមួយខែ សម្រាប់ខែដែលនិយោជកមិនបានផ្តល់ ជូនកម្មករនិយោជិតម្តងម្កាល នៅពេលដែលនិយោជកមិនមានការងារឱ្យកម្មករនិយោជិតធ្វើ និងឱ្យរង់ចាំរហូតដល់មានការងារធ្វើ។
    - កន្លងមក និយោជកតែងតែផ្តល់ប្រាក់រង់ចាំការងារ ដល់កម្មករនិយោជិត ចំនួន ២០ ដុល្លារអាមេរិក ក្នុងមួយខែ រៀងរាល់ខែដែលនិយោជកឱ្យកម្មករនិយោជិតរង់ចាំពេលមិនមានការងារឱ្យធ្វើ។
    - នៅពេលដែលនិយោជកបានបញ្ចប់ទំនាក់ទំនងការងារជាមួយកម្មករនិយោជិតម្តងម្កាលចំនួន ២០ នាក់ និយោជកមិនបានបើកផ្តាច់នូវប្រាក់រង់ចាំការងារ ជូនកម្មករនិយោជិតនៅក្នុងខែមិថុនា និងខែកក្កដា ឆ្នាំ២០២០ ដូចបានសន្យានោះទេ ដោយមូលហេតុនិយោជកមិនមានប្រាក់សម្រាប់បើកជូន។
- ភាគីកម្មករនិយោជិតបានដាក់បញ្ជីឈ្មោះកម្មករនិយោជិតដែលទាមទារនៅក្នុងចំណុចនេះមានកម្មករនិយោជិតសរុបចំនួន ១៤ នាក់ មានឈ្មោះ៖ ទុយ វង្ឋា អត្តលេខ L4.001, ឌី សំបុក អត្តលេខ CT.021, ទូច ភា អត្តលេខ H.001, យូ វុទ្ធី អត្តលេខ L1.052, យ៉ង ញ៉ៅ អត្តលេខ L6.037, ចាន់ វុទ្ធី អត្តលេខ CT.016, វង់ ចាន់ណា អត្តលេខ CT.027, យ៉ត សុភារិន អត្តលេខ CT.039, យឿន ពៅ អត្តលេខ WH.011, វ៉ុន ចាន់ដារា អត្តលេខ HI.036, សន រិះ អត្តលេខ L2.113, ណុប ផ្លា អត្តលេខ WH.005, ជាង សុភក្តិ អត្តលេខ HI.002 និង ជា សុភណ្ឌ័ អត្តលេខ HI.017។

ចំណុចវិវាទទី ៣ ៖ ស្នើសុំឱ្យក្រុមហ៊ុនបង់ប្រាក់ភាគទានជូន ប.ស.ស. ឱ្យបានគ្រប់ចំនួនកម្មករនិយោជិត ដើម្បីអោយកម្មករនិយោជិតអាចប្រើប្រាស់សេវា ប.ស.ស. ព្រោះជាងមួយឆ្នាំហើយបងប្អូនកម្មករនិយោជិតគ្មានសេវានេះប្រើប្រាស់នោះទេ

- ភាគីកម្មករនិយោជិតបញ្ជាក់ការទាមទារ ឱ្យនិយោជកបង់ប្រាក់ភាគទានជូន ប.ស.ស. ឱ្យបានទៀងទាត់ ដើម្បីឱ្យកម្មករនិយោជិតអាចប្រើប្រាស់សេវារបស់ ប.ស.ស.។
- ភាគីកម្មករនិយោជិតបានបញ្ជាក់ថា ៖
    - និយោជកមានកាតព្វកិច្ចបង់ប្រាក់ភាគទានជូន ប.ស.ស. ប៉ុន្តែនិយោជកមិនបានបង់ប្រាក់ភាគទាននេះចាប់ពីខែកក្កដា ឆ្នាំ២០១៩ មកម្លេះ ពីព្រោះនិយោជកបានប្រាប់កម្មករនិយោជិតថា និយោជកមិនមានប្រាក់បង់ប្រាក់ភាគទានជូន ប.ស.ស. ទេ។

- ពីមុនកម្មករនិយោជិតដែលមានផ្ទៃពោះ អាចប្រើប្រាស់សេវារបស់ ប.ស.ស. បាន ប៉ុន្តែសម្រាប់កម្មករនិយោជិតធម្មតា គឺមិនអាចប្រើប្រាស់បានទេ ដោយមន្ទីរពេទ្យជាដៃគូរបស់ ប.ស.ស. បានបញ្ជាក់ថា និយោជកមិនបានបង់ប្រាក់ភាគទានជូន ប.ស.ស. ទេ។
- មន្ត្រីរបស់ ប.ស.ស. ធ្លាប់បានទៅដល់ក្រុមហ៊ុន ហើយនិយោជកបានបញ្ជាក់ប្រាប់មន្ត្រីរបស់ ប.ស.ស. ថានិយោជកមិនមានប្រាក់ដើម្បីបង់ភាគទានជូន ប.ស.ស. នោះទេ។

## ហេតុផលនៃសេចក្តីសម្រេច ៖

មុននឹងពិចារណាចំណុចទាមទារនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបកស្រាយអំពីនីតិវិធីអាជ្ញាកណ្តាល នៅពេលអវត្តមានភាគីនិយោជក និងដើមបណ្តឹងជាមុនសិន ៖

ក. <u>ការអវត្តមានភាគីនិយោជក</u>

ប្រការ ២១ នៃប្រកាសលេខ ០៩៩ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ចែងថា ៖ *"ក្នុងករណីភាគីណាមួយ បានទទួលការអញ្ជើញត្រឹមត្រូវហើយ តែបែរជាខកខានមិនបានបង្ហាញខ្លួន នៅចំពោះមុខក្រុមអាជ្ញាកណ្តាល ដោយគ្មានបង្ហាញមូលហេតុត្រឹមត្រូវ ក្រុមអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួនក្នុងពេលដែលភាគីនោះអវត្តមាន ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាលដោយចេញសេចក្តីបង្គាប់"* ។

ទាក់ទងនឹងខ្លឹមសារនៃប្រការ២១ នៃប្រកាសលេខ ០៩៩ នៅក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាល បានបកស្រាយថា នៅពេលដែលភាគីនិយោជកបានទទួលការអញ្ជើញត្រឹមត្រូវហើយ តែបែរជាខកខានមិនបានបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល ដោយគ្មានបង្ហាញមូលហេតុត្រឹមត្រូវ ក្រុមអាជ្ញាកណ្តាលអាចសម្រេចបន្តដំណើរការរបស់ខ្លួន ដោយធ្វើការបើកសវនាការកំបាំងមុខភាគីនិយោជកដែលអវត្តមាននោះបាន។ *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ៥៣/០៤-គួង ហុង, លេខ ១៤៨/០៧-ប៉ាយ ហឺ, លេខ ៩៩/០៩-យឺង ឡែន, លេខ ១៧៣/១១-ជិន អ៊ីង, លេខ ១៤២/១២-អប្សរា, លេខ ១០៩/១៣-វិទ្យាស្ថាន ប៊ុណ្ណា កម្ពុជា, លេខ ១៦៣/១៤-ស៊ីន ឆាង ស៊ីង ហ្គាមេន (ខេមបូឌា), លេខ ២៥០/១៥-អិល អិល អេស ព្រីនធីង, លេខ ០២២/១៦-អាត់តាខឹស (ខេមបូឌា) ហ្គាមេន)*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របតាមការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅក្នុងសំណុំរឿងខាងលើនេះដែរ។ នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញលិខិតអញ្ជើញ និងជូនដំណឹងត្រឹមត្រូវតាមនីតិវិធីដល់ភាគីនិយោជក នូវព័ត៌មានអំពីកាលបរិច្ឆេទនៃសវនាការ, ទីកន្លែងនៃសវនាការ ព្រមទាំងលេខទូរសព្ទ/ទូរសារ សម្រាប់ទំនាក់ទំនងមកក្រុមប្រឹក្សាអាជ្ញាកណ្តាល និងបានទូរសព្ទទាក់ទងទៅតំណាងភាគីនិយោជក ដើម្បីបញ្ជាក់អំពីការចូលរួមសវនាការ នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២០ ប៉ុន្តែតំណាងភាគីនិយោជកបានបញ្ជាក់ថា ពុំបានចូលរួមសវនាការទេ ព្រោះនិយោជកមិននៅក្រុមហ៊ុនទេ ហើយគ្មានអ្នកដែលមានសិទ្ធិអាចចេញលិខិតផ្ទេរសិទ្ធិឱ្យប្រធានផ្នែករដ្ឋបាល តំណាងឱ្យនិយោជកចូលរួមសវនាការបាននោះទេ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីនិយោជកបានទទួលការអញ្ជើញត្រឹមត្រូវហើយ។

សរុបសេចក្តីមកយោងតាមប្រការ ២១ នៃប្រកាសលេខ ០៩៩ និងការបកស្រាយរបស់អាជ្ញាកណ្តាលក្នុងសេចក្តីបង្គាប់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចបន្តដំណើរការរបស់ខ្លួន ក្នុងពេលដែលភាគីនិយោជកអវត្តមាន ដោយគ្មានហេតុផលត្រឹមត្រូវ។

ខ. <u>ដើមបណ្តឹង</u>

THE ARBITRATION COUNCIL

នៅក្នុងបណ្តឹងដើមរបស់កម្មករនិយោជិត កម្មករនិយោជិតដែលបានផ្តិតស្នាមមេដៃទាមទារ សរុបចំនួន ១៨០ នាក់ ដោយនាយកដ្ឋានវិវាទការងារ បានចេញលិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម លេខ ៦៦៤ ក.ប/អក/វក ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២០ ដែលមានឈ្មោះកម្មករនិយោជិតចំនួន ៥ នាក់ ដូចជា ៖ លោកស្រី វង់ ស៊ីនួន, លោក ឌុត វ៉ិត, លោក ម៉េង ហួត, លោក យែម-ចន្ទា, លោក ទូច ភា និង លោក ទុយ វង្ឍា។

ប្រការ១ នៃប្រកាសលេខ ៣៦២ ក.ប/ប្រ.ក ស្តីពីការផ្ទេរប្រតិភូកម្ម មុខងារក្នុងការធ្វើបណ្តឹងអំពីវិវាទការងាររួម និងចេញលិខិតទទួលស្គាល់ប្រតិភូក្រុមប្រឹក្សាចរចា ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៦ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចែងថា ៖ *"ត្រូវបានផ្ទេរប្រតិភូកម្មជូនដល់ប្រធាននាយកដ្ឋានវិវាទការងារ និងប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត នូវមុខងារ ដូចខាងក្រោម ៖*

...

*- ចេញលិខិតទទួលស្គាល់ប្រតិភូក្រុមប្រឹក្សាចរចា សម្រាប់ដោះស្រាយវិវាទការងាររួម។"*។

យោងតាមប្រការ១ នៃប្រកាសលេខ ៣៦២ ក.ប/ប្រ.ក ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ថា នាយកដ្ឋានវិវាទការងារ និងប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត មានមុខងារក្នុងការទទួលស្គាល់កម្មករនិយោជិត ឱ្យធ្វើជាតំណាងរបស់ភាគីកម្មករនិយោជិត ដើម្បីដោះស្រាយវិវាទការងាររួម។ ដូច្នេះ កម្មករនិយោជិតដែលត្រូវបានទទួលស្គាល់ដោយនាយកដ្ឋានវិវាទការងារ ឬប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត មានសិទ្ធិស្របច្បាប់ក្នុងការតំណាងឱ្យភាគីកម្មករនិយោជិត ដើម្បីដោះស្រាយវិវាទការងាររួម ដោយរួមទាំងនៅដំណាក់កាលដោះស្រាយវិវាទការងារនៅក្រុមប្រឹក្សាអាជ្ញាកណ្តាលផងដែរ។ *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាល លេខ ២២៣/១៦-យូនីកតា ថេកណូឡូជី (ខេមបូឌា), លេខ ២២៤/១៦-កាស៊ីណូកោះមាស និង សណ្ឋាគារ, លេខ ០០៨/១៧-ថបវើលដ៍ ហ្គាមិន (ខេមបូឌា) អិលធីឌី និងលេខ ២៣៧/១៦-ហ្សិណា-ដាយដុង (ខេមបូឌា) អេឡិចត្រូនិច)*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របទៅនឹងការបកស្រាយរបស់ក្រុមប្រឹក្សា-អាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗ ខាងលើដែរ។

នាយកដ្ឋានវិវាទការងារបានចេញលិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម លេខ ៦៦៤ ក.ប/អក/វក ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២០ ដែលមានអ្នកតំណាងកម្មករនិយោជិតចំនួន ៥ នាក់ ដូចជា ៖ លោកស្រី វង់ ស៊ីនួន, លោក ឌុត វ៉ិត, លោក ម៉េង ហួត, លោក យែម ចន្ទា, លោក ទូច ភា និង លោក ទុយ វង្ឍា ជាអ្នកតំណាងភាគីកម្មករនិយោជិតនៃក្រុមហ៊ុន យ៉ាំង ដុង ១ ខូអិលធីឌី។ នៅថ្ងៃសវនាការអាជ្ញាកណ្តាល គឺមានវត្តមានរបស់កម្មករនិយោជិតដែលជាអ្នកតំណាងភាគីកម្មករនិយោជិតចំនួន ១ នាក់ គឺឈ្មោះ វង់ ស៊ីនួន ដែលមានឈ្មោះនៅក្នុងលិខិតបញ្ជាក់អ្នកតំណាងខាងលើ។

ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា កម្មករនិយោជិត វង់ ស៊ីនួន គឺមានសិទ្ធិធ្វើជាតំណាងកម្មករនិយោជិតនៃក្រុមហ៊ុន យ៉ាំង ដុង ១ ខូអិលធីឌី ក្នុងការដោះស្រាយវិវាទការងាររួមនៅក្រុមប្រឹក្សាអាជ្ញា-កណ្តាល ស្របតាមប្រការ១ នៃប្រកាសលេខ ៣៦២ ក.ប/ប្រ.ក ខាងលើ។

ចំណុចវិវាទទី ១ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកសងរំលឹកប្រាក់ឈ្នួលឈប់សម្រាកលំហែមាតុភាព ចំនួន ៥០ ភាគរយ រយៈពេល ៣ ខែ និងប្រាក់បំណាច់មាតុភាព ប.ស.ស. ចំនួន ៧០ ភាគរយ ជូនកម្មករនិយោជិតដែលបានឈប់សម្រាកលំហែមាតុភាពរួច

តាមការអះអាងរបស់ភាគីកម្មករនិយោជិតនៅក្នុងសវនាការ កម្មករនិយោជិតដែលទាមទារនៅក្នុងចំណុចនេះមានចំនួន ២០ នាក់។ ដោយឡែកនៅថ្ងៃដាក់ឯកសារ ភាគីកម្មករនិយោជិតបានដាក់បញ្ជីឈ្មោះបញ្ជាក់ចំនួនកម្មករនិយោជិតដែលទាមទាចំណុចនេះមានសរុប ៨ នាក់។ ក្រោយពីបានពិនិត្យមើល និងផ្ទៀងផ្ទាត់ព័ត៌មានរបស់កម្មករនិយោជិតនៅក្នុងបណ្តឹងដើមដែលមានស្នាមមេដៃ និងបញ្ជីឈ្មោះបញ្ជាក់ចំនួនកម្មករនិយោជិតដែលទាមទារក្នុងចំណុចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា កម្មករនិយោជិតដែលបានផ្តិតស្នាមមេដៃទាមទារ និងមានឈ្មោះក្នុងបញ្ជីឈ្មោះបញ្ជាក់អ្នកទាមទារចំណុចនេះ គឺមានចំនួន ៣ នាក់ មានឈ្មោះ យ៉ែម ចាន់ជា អត្តលេខ L4.049, ផៃ សារិន អត្តលេខ L6.001 និង វឿន ធារី អត្តលេខ L4.007។ ហេតុដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងពិចារណាការទាមទារចំណុចនេះសម្រាប់តែកម្មករនិយោជិតចំនួន ៣ នាក់នេះប៉ុណ្ណោះ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើនិយោជកមានកាតព្វកិច្ចសងរំលឹកប្រាក់ឈ្នួលឈប់សម្រាកលំហែមាតុភាពចំនួន ៥០ ភាគរយ ជូនកម្មករនិយោជិតដែលបានឈប់សម្រាកលំហែមាតុភាពដែរ ឬ ទេ?

កថាខណ្ឌទី១ មាត្រា ១៨២ នៃច្បាប់ស្តីពីការងារ ឆ្នាំ១៩៩៧ ចែងថា ៖ *"ក្នុងសហគ្រាសទាំងអស់ ដែលមានរាប់ក្នុងមាត្រា១ នៃច្បាប់នេះ ស្ត្រីទាំងឡាយត្រូវមានសិទ្ធិឈប់សម្រាកកៅសិបថ្ងៃ ដើម្បីសំរាលកូន"*។

មាត្រា ១៨៣ នៃច្បាប់ស្តីពីការងារដដែល ចែងថា ៖ *"ក្នុងពេលដែលឈប់សម្រាក ដូចមានចែងក្នុងមាត្រាខាងលើនេះ ស្ត្រីមានសិទ្ធិត្រូវបានប្រាក់ឈ្នួលពាក់កណ្តាល គិតទាំងប្រាក់បន្ទាប់បន្សំផង ដោយនិយោជកបើកឱ្យ។*

*...*

*ក៏ប៉ុន្តែ ការទទួលប្រាក់ឈ្នួលដូចមានចែងក្នុងកថាខ័ណ្ឌទី១ នៃមាត្រានេះ នឹងឱ្យបានតែចំពោះស្ត្រីណាដែលធ្វើការក្នុងសហគ្រាសបានយ៉ាងតិចមួយឆ្នាំរៀងមក"*។

យោងតាមមាត្រា ១៨២ និងមាត្រា ១៨៣ នៃច្បាប់ស្តីពីការងារខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា និយោជកមានកាតព្វកិច្ចផ្តល់ប្រាក់ឈ្នួលពាក់កណ្តាល គិតទាំងប្រាក់បន្ទាប់បន្សំជូនដល់កម្មករនិយោជិតដែលត្រូវឈប់សម្រាកលំហែមាតុភាពរយៈពេល ៩០ ថ្ងៃ។ យ៉ាងណាមិញ មាត្រាទាំងនេះ មិនបានបញ្ជាក់អំពីពេលវេលា ដែលនិយោជកត្រូវបើកប្រាក់ឈ្នួលឈប់សម្រាកលំហែមាតុភាព ឱ្យកម្មករនិយោជិតជាស្ត្រីដែលឈប់សម្រាកលំហែមាតុភាពនោះទេ។

តាមអង្គហេតុ កម្មករនិយោជិតបញ្ជាក់ថា និយោជកធ្លាប់ទូទាត់ប្រាក់ឈ្នួលឈប់សម្រាកលំហែមាតុភាពជូនកម្មករនិយោជិតនៅឆ្នាំ២០១៨ តែចាប់ពីឆ្នាំ២០១៩ មក និយោជកមិនបានទូទាត់ជូនកម្មករនិយោជិតនោះទេ។ ហេតុនេះ ពួកគាត់ទាមទារឱ្យនិយោជកសងរំលឹកប្រាក់ឈ្នួលឈប់សម្រាកលំហែមាតុភាពដែលនិយោជកមិនទាន់ទូទាត់ឱ្យពួកគាត់ចំនួន ៥០ ភាគរយ សម្រាប់រយៈពេល ៣ ខែ។ ដោយភាគីនិយោជកអវត្តមានក្នុងសវនាការ ដូចនេះមិនមានការឆ្លើយតបពីភាគីនិយោជកចំពោះការអះអាងនេះទេ។ យោងតាមបញ្ជីឈ្មោះបញ្ជាក់អ្នកទាមទារកម្មករនិយោជិតឈ្មោះ យ៉ែម ចាន់ជា បានចូលធ្វើការនៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៥ និងបានឈប់សម្រាកលំហែមាតុភាពនៅថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២០ បច្ចុប្បន្នកំពុងឈប់សម្រាកលំហែមាតុភាព, ផៃ សារិន បានចូលធ្វើការនៅថ្ងៃទី២ ខែសីហា ឆ្នាំ២០១០ និងបានឈប់សម្រាកលំហែមាតុភាពនៅថ្ងៃទី១ ខែតុលា ឆ្នាំ២០១៩ បច្ចុប្បន្នបានត្រលប់ចូលធ្វើការវិញ និង វឿន ធារី បានចូលធ្វើការនៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១០ និងបានឈប់សម្រាកលំហែមាតុភាពនៅថ្ងៃទី១ ខែតុលា ឆ្នាំ២០១៩ បច្ចុប្បន្នបានត្រលប់ចូលធ្វើការវិញ។

THE ARBITRATION COUNCIL

យោងតាមមាត្រាខាងលើ អង្គហេតុ និងបញ្ជីឈ្មោះបញ្ជាក់អ្នកទាមទារ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា កម្មករនិយោជិតឈ្មោះ យ៉ែម ចាន់ធា, ឆៃ សារិន និង ជឿន ធារី គឺបានធ្វើការលើសពីមួយឆ្នាំ និងមានសិទ្ធិទទួលបានប្រាក់ឈ្នួលឈប់សម្រាកលំហែមាតុភាពចំនួន ៥០ ភាគរយ រយៈពេល ៣ ខែ ដែលនិយោជកមានកាតព្វកិច្ចផ្តល់ជូនកម្មករនិយោជិតស្ត្រីដែលឈប់សម្រាកលំហែមាតុភាព។ តាមការអះអាងរបស់ភាគីកម្មករនិយោជិត និយោជកមិនទាន់បានទូទាត់ប្រាក់ឈ្នួលឈប់សម្រាកលំហែមាតុភាពចំនួន ៥០ ភាគរយ រយៈពេល ៣ ខែនេះ ជូនកម្មករនិយោជិតឈ្មោះ យ៉ែម ចាន់ធា, ឆៃ សារិន និង ជឿន ធារី នៅឡើយទេ។

ហេតុដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា និយោជកមានកាតព្វកិច្ចត្រូវសងរំលឹកប្រាក់ឈ្នួលឈប់សម្រាកលំហែមាតុភាពចំនួន ៥០ ភាគរយ រយៈពេល ៣ ខែ ជូនកម្មករនិយោជិត។

លើសពីនេះ នៅក្នុងសវនាការ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកសងរំលឹកប្រាក់បំណាច់មាតុភាព ប.ស.ស. ដែលនិយោជកមិនទាន់បានទូទាត់ជូនកម្មករនិយោជិត។

មុននឹងពិចារណាលើការទាមទារនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាជាមុនសិនថា តើក្រុមប្រឹក្សាអាជ្ញាកណ្តាលមានយុត្តាធិការដោះស្រាយវិវាទនេះដែរ ឬទេ?

មាត្រា ៩១ នៃច្បាប់ស្តីពីរបបសន្តិសុខសង្គមដដែរ ចែងថា ៖ "*វិវាទឬបណ្តឹងដែលទាក់ទងនឹងការអនុវត្តបទប្បញ្ញត្តិនានានៃរបបសន្តិសុខសង្គមរវាងសមាជិក ប.ស.ស. និយោជក និង ប.ស.ស. ត្រូវដោះស្រាយដោយគណៈកម្មការដោះស្រាយវិវាទនៃ ប.ស.ស. ។ ក្នុងករណីមិនមានការសះជាវិវាទឬបណ្តឹងនោះអាចត្រូវបានប្តឹងទៅនិយ័តករសន្តិសុខសង្គម ដែលសមាជិក ប.ស.ស. កំពុងធ្វើការងារ មុននឹងប្តឹងទៅសាលាដំបូងនៃរាជធានី ខេត្ត*"។

ផ្អែកលើខ្លឹមសារនៃមាត្រា ៩១ ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា វិវាទ ឬបណ្តឹងដែលទាក់ទងនឹងការអនុវត្តបទប្បញ្ញត្តិនានានៃរបបសន្តិសុខសង្គមរវាងសមាជិក ប.ស.ស. និយោជក និង ប.ស.ស. គឺស្ថិតនៅក្រោមសមត្ថកិច្ចរបស់គណៈកម្មការដោះស្រាយវិវាទ ឬបណ្តឹង ប.ស.ស. ហើយប្រសិនបើមិនអាចដោះស្រាយបានដោយគណៈកម្មការនេះ វិវាទ ឬបណ្តឹង ប.ស.ស. ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចនិយ័តករសន្តិសុខសង្គម ដែលសមាជិក ប.ស.ស. កំពុងធ្វើការ មុននឹងប្តឹងទៅដល់តុលាការ។ *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ៤៤/១៧-ហ្គួយវណ្ណដា គ្រេនស្ពត អិចប្រេស ខូអិលធីឌី ហេតុផលនៃចំណុចវិវាទទី២)*

នៅក្នុងសំណុំរឿងនេះ ភាគីកម្មករនិយោជិត គឺជាភាគីដើមបណ្តឹង ដែលបានប្តឹងទាមទារឱ្យនិយោជកសងរំលឹកប្រាក់បំណាច់មាតុភាព ពីព្រោះនិយោជកមិនបានបង់ប្រាក់ភាគទានជូន ប.ស.ស.។ បើទោះបីជាវិវាទនេះ ជាវិវាទរវាងកម្មករនិយោជិត និងនិយោជកក្តី ប៉ុន្តែផ្អែកលើខ្លឹមសារនៃមាត្រា ៩១ ខាងលើ ការដែលនិយោជកខកខានមិនបានបង់ប្រាក់ភាគទានចូល ប.ស.ស. បង្ហាញថា វិវាទនេះ ជាវិវាទរវាង ប.ស.ស. និងនិយោជក ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់គណៈកម្មការដោះស្រាយវិវាទ ឬបណ្តឹង នៃប.ស.ស. ជាស្ថាប័នទទួលបន្ទុក។ ក្នុងករណីដែលវិវាទ មិនអាចដោះស្រាយបានដោយគណៈកម្មការដោះស្រាយវិវាទនេះទេ វិវាទនេះ ត្រូវទទួលបន្ទុកដោះស្រាយបន្តដោយនិយ័តករសន្តិសុខសង្គម ដែលសមាជិក ប.ស.ស. កំពុងធ្វើការ មុននឹងប្តឹងទៅតុលាការ។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនមានយុត្តាធិការដោះស្រាយវិវាទទាក់ទងនឹងការមិនអនុវត្តបទប្បញ្ញត្តិនៃច្បាប់ស្តីពីរបបសន្តិសុខសង្គមនោះឡើយ។

ជាសរុប ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បង្គាប់ឱ្យនិយោជកសងរំលឹកប្រាក់ឈ្នួលឈប់សម្រាកមាតុភាពចំនួន ៥០ ភាគរយ រយៈពេល ៣ ខែ ជូនកម្មករនិយោជិតស្ត្រីដែលបានឈប់សម្រាកលំហែមាតុភាព

និងបដិសេធពិចារណាលើការទាមទាររបស់ភាគីកម្មករនិយោជិតឱ្យនិយោជកសងរំលឹកប្រាក់បំណាច់មាតុភាព ប.ស.ស. ចំនួន ៧០ ភាគរយ។

ចំណុចវិវាទទី ២ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកផ្តល់ប្រាក់រង់ចាំការងារចំនួន ២០ ដុល្លារអាមេរិក ក្នុងមួយខែ សម្រាប់ខែមិថុនា និងខែកក្កដា ឆ្នាំ២០២០ តាមការសន្យាដោយផ្ទាល់មាត់របស់និយោជក ជូនកម្មករនិយោជិតម្តងម្កាលចំនួន ២០ នាក់

តាមការអះអាងរបស់ភាគីកម្មករនិយោជិតនៅក្នុងសវនាការ កម្មករនិយោជិតដែលទាមទារនៅក្នុងចំណុចនេះមានចំនួន ២០ នាក់។ ដោយឡែកនៅថ្ងៃដាក់ឯកសារ ភាគីកម្មករនិយោជិតបានដាក់បញ្ជីឈ្មោះបញ្ជាក់អ្នកទាមទារដែលមានកម្មករនិយោជិតសរុបចំនួន ១៤ នាក់។ ក្រោយពីបានពិនិត្យ និងផ្ទៀងផ្ទាត់ជាមួយនឹងស្នាមមេដៃរបស់កម្មករនិយោជិតនៅក្នុងពាក្យបណ្តឹងដើម ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ក្នុងចំណោមកម្មករនិយោជិតចំនួន ១៤ នាក់នៅក្នុងបញ្ជីឈ្មោះខាងលើ មានកម្មករនិយោជិតចំនួន ៧ នាក់ ឈ្មោះ ទុយ វណ្ណា អត្តលេខ L4.001, ទូច ភា អត្តលេខ H.001, ចាន់ វុទ្ធី អត្តលេខ CT.016, វង់ ចាន់ណា អត្តលេខ CT.027, យឿន ពៅ អត្តលេខ WH.011, រ៉ុន ចាន់ដារា អត្តលេខ HI.036 និង ជា សុភ័ណ្ឌ អត្តលេខ HI.017 ដែលមានឈ្មោះនៅក្នុងពាក្យបណ្តឹងដើម។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងពិចារណាចំណុចទាមទារនេះសម្រាប់កម្មករនិយោជិតចំនួន ៧ នាក់។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើមានការព្រមព្រៀងរវាងនិយោជក និងកម្មករនិយោជិត ដែលបង្កើតជាកាតព្វកិច្ចឱ្យនិយោជកត្រូវសងរំលឹកប្រាក់រង់ចាំការងារចំនួន ២០ ដុល្លារអាមេរិក សម្រាប់ខែមិថុនា និងខែកក្កដា ឱ្យកម្មករនិយោជិតដែលរង់ចាំពេលនិយោជកមិនមានការងារឱ្យធ្វើដែរ ឬទេ?

មាត្រា ៣១១ នៃក្រមរដ្ឋប្បវេណី ចែងថា ៖ "*កិច្ចសន្យា គឺជាកិរិយាដែលបុគ្គលពីនាក់ ឬ ច្រើន នាក់មានឆន្ទៈត្រូវគ្នា ព្រមបង្កើត កែប្រែ និងរំលាយនូវកាតព្វកិច្ច*"។

មាត្រានេះ មានន័យថា កិច្ចសន្យា កើតឡើងដោយសារឆន្ទៈរបស់ភាគី ហើយភាគីអាចបង្ហាញឆន្ទៈព្រមព្រៀងគ្នាបង្កើត ការកែប្រែ និងរំលាយនូវកាតព្វកិច្ចបានផងដែរ។

មាត្រា ៣៣៦ នៃក្រមរដ្ឋប្បវេណី ដដែលកំណត់ថា ៖ "*កិច្ចសន្យាមានអានុភាពដោយសារសំណើ និងស្វីការត្រូវគ្នា*"។

មាត្រានេះមានន័យថា កិច្ចសន្យាអាចធ្វើទៅបាន លុះត្រាណាតែមានការព្រមព្រៀងគ្នារវាងអ្នកធ្វើសំណើនិងអ្នកធ្វើស្វីការ។

តាមអង្គហេតុ ភាគីកម្មករនិយោជិតបានអះអាងថា និយោជកបានសន្យាដោយផ្ទាល់មាត់ថានឹងផ្តល់ប្រាក់រង់ចាំការងារចំនួន ២០ ដុល្លារអាមេរិក ក្នុងមួយខែ ជូនកម្មករនិយោជិត រៀងរាល់ខែដែលនិយោជកឱ្យកម្មករនិយោជិតរង់ចាំការងារពេលមិនមានការងារឱ្យធ្វើ រហូតដល់ពេលនិយោជកមានការងារឱ្យធ្វើវិញ។ ប៉ុន្តែសម្រាប់ខែមិថុនា និងខែកក្កដា និយោជកមិនបានផ្តល់ជូនកម្មករនិយោជិតនោះទេ ហើយនិយោជកក៏បានរំសាយពួកគាត់មិនឱ្យរង់ចាំការងារទៀតផងដែរ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីដែលធ្វើការអះអាង ឬចោទប្រកាន់ គឺមានបន្ទុកភស្តុតាង។ *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាល លេខ ៧៩/០៥-អេវើហ្គ្រីន, លេខ ១០១/០៨-ជីឌីអ៊ឹម ហេតុផលនៃចំណុចវិវាទទី១ និងទី២, លេខ ១៦៨/០៩-ទីកប្លា ផ្កាហ្សា ហេតុផលនៃចំណុចវិវាទទី២, លេខ ១១៥/១០-ជីហ្វម៉ូស ហេតុផលនៃចំណុចវិវាទទី១៨, លេខ ១៤៨/១១-ដាយ យ៉ាំង, លេខ ២៧៦/១៥-មិត្តភាព ហ្គាមិន*

THE ARBITRATION COUNCIL

*ហេតុផលនៃ ចំណុចវិវាទទី១, លេខ ០៩៣/១៦-ខេម រើណា ហ្វេសិន ខូអិលធីឌី ហេតុផលនៃចំណុចវិវាទទី៣ និង លេខ ១៧១/១៦- ដេវើលីន ខូអិលធីឌី)*

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលនៅក្នុងសំណុំរឿងមុនៗ បានបដិសេធការទាមទារ ឬច្រានចោលការអះអាង របស់ភាគីវិវាទ ប្រសិនបើភាគីដែលធ្វើការទាមទារ ឬធ្វើការអះអាងនោះ មិនមានមូលដ្ឋានគ្រប់គ្រាន់ ឬភស្តុតាង ជាក់លាក់ ដើម្បីគាំទ្រនូវការទាមទារ ឬការអះអាងរបស់ខ្លួន។ *(សូមមើលសេចក្ដីបង្គាប់អាជ្ញាកណ្ដាល លេខ ៦៣/០៤-សាញ វ៉ែល ហេតុផលនៃចំណុចវិវាទទី៤, លេខ ៩៩/០៦-សៅធ៍ បាយ ហេតុផលនៃចំណុចវិវាទទី៥, លេខ ៣៣/០៧-ហ្គោលហ្វេម ហេតុផលនៃចំណុចវិវាទទី៤, លេខ ៥១/០៧-ហ្គោលហ្វេម ហេតុផលនៃចំណុច វិវាទទី៣ និងលេខ ០៣២/១៦-អ៊ីជើនិធី ក្លូបិល ស្ពត់ធីង (ខេមបូឌា) ខូអិលធីឌី ហេតុផលនៃចំណុចវិវាទទី១)*

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របទៅនឹងការបកស្រាយរបស់ក្រុមប្រឹក្សា-អាជ្ញាកណ្ដាលនៅក្នុងសំណុំរឿងមុនៗខាងលើដែរ។

ករណីនេះ ក្រៅពីការអះអាងនៅក្នុងសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលរកឃើញថា ភាគីកម្មករ និយោជិតមិនបានបង្ហាញភស្តុតាងជាក់លាក់ណាមួយបញ្ជាក់ថា ពិតជាមានការព្រមព្រៀងរវាងនិយោជក និង កម្មករនិយោជិត ដែលអាចឱ្យក្រុមប្រឹក្សាអាជ្ញាកណ្ដាលជឿបានថា និយោជកពិតជាបានព្រមព្រៀងបង្កើតកិច្ច សន្យាជាមួយកម្មករនិយោជិតក្នុងការផ្ដល់ប្រាក់រង់ចាំការងារចំនួន ២០ ដុល្លារអាមេរិក ក្នុងមួយខែ រៀងរាល់ខែ សម្រាប់ពេលកម្មករនិយោជិតរង់ចាំការងារ រហូតដល់និយោជកមានការងារឱ្យធ្វើនោះទេ។ ដោយហេតុថាគ្មាន កិច្ចព្រមព្រៀង ក្រុមប្រឹក្សាអាជ្ញាកណ្ដាយល់ឃើញថា និយោជកមិនមានកាតព្វកិច្ចសងប្រាក់រង់ចាំការងារចំនួន ២០ ដុល្លារអាមេរិក ជូនកម្មករនិយោជិតសម្រាប់ខែមិថុនា និងខែកក្កដា ឆ្នាំ២០២០ ដែលនិយោជកបានរំសាយ នោះទេ។

ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលសម្រេច បដិសេធការទាមទាររបស់ភាគីកម្មករនិយោជិតឱ្យនិយោជក សងប្រាក់រង់ចាំការងារចំនួន ២០ ដុល្លារអាមេរិក សម្រាប់ខែមិថុនា និងខែកក្កដា ឆ្នាំ២០២០ ដែលនិយោជកបាន រំសាយពួកគាត់។

ចំណុចវិវាទទី ៣ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកបង់ប្រាក់ភាគទានជូន ប.ស.ស. ឱ្យបានទៀងទាត់ ដើម្បីឱ្យកម្មករនិយោជិតអាចប្រើប្រាស់សេវារបស់ ប.ស.ស.

មុននឹងក្រុមប្រឹក្សាអាជ្ញាកណ្ដាលពិចារណាទៅលើការទាមទារនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលពិចារណា ជាមុនសិនថា តើក្រុមប្រឹក្សាអាជ្ញាកណ្ដាលមានយុត្តាធិការដោះស្រាយវិវាទនេះដែរ ឬទេ?

*(សូមមើលការបកស្រាយមាត្រា ៩១ នៃច្បាប់ស្ដីពីរបបសន្តិសុខសង្គម ឆ្នាំ២០១៩ អំពីនីតិវិធីដោះ ស្រាយវិវាទទាក់ទងនឹងការអនុវត្តបទប្បញ្ញត្តិនានានៃរបបសន្តិសុខសង្គម នៅក្នុងចំណុចវិវាទទី១ ខាងលើ។)*

ករណីនេះ ភាគីកម្មករនិយោជិត គឺជាភាគីដើមបណ្ដឹង ដែលបានប្ដឹងទាមទារឱ្យនិយោជកបង់ប្រាក់ ភាគទានជូន ប.ស.ស. ឱ្យបានទៀងទាត់ ដើម្បីឱ្យកម្មករនិយោជិតអាចប្រើប្រាស់សេវារបស់ ប.ស.ស. បាន។ បើទោះបីជាវិវាទនេះ ជាវិវាទរវាងកម្មករនិយោជិត និងនិយោជកក្ដី ប៉ុន្តែផ្អែកលើខ្លឹមសារនៃមាត្រា ៩១ ខាងលើ ការដែលនិយោជកខកខានមិនបានបង់ប្រាក់ភាគទានចូល ប.ស.ស. បង្ហាញថា វិវាទនេះ ជាវិវាទរវាង ប.ស.ស. និងនិយោជក ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់គណៈកម្មការដោះស្រាយវិវាទ ឬបណ្ដឹង នៃ ប.ស.ស. ជា ស្ថាប័នទទួលបន្ទុក។ ក្នុងករណីដែលវិវាទ មិនអាចដោះស្រាយបានដោយគណៈកម្មការដោះស្រាយវិវាទនេះទេ វិវាទនេះ ត្រូវទទួលបន្ទុកដោះស្រាយបន្តដោយនិយ័តករសន្តិសុខសង្គម ដែលសមាជិក ប.ស.ស. កំពុងធ្វើការ

THE ARBITRATION COUNCIL

មុននឹងប្តឹងទៅតុលាការ។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនមានយុត្តាធិការដោះស្រាយវិវាទទាក់ទងនឹងការមិនអនុវត្តបទប្បញ្ញត្តិនៃច្បាប់ស្តីពីរបបសន្តិសុខសង្គមនោះឡើយ។

ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បដិសេធពិចារណាការទាមទាររបស់ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកបង់ប្រាក់ភាគទានជូន ប.ស.ស. ឱ្យបានទៀងទាត់ ដើម្បីឱ្យកម្មករនិយោជិតអាចប្រើប្រាស់សេវារបស់ ប.ស.ស.។

យោងតាមអង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចដូចតទៅ ៖

## សម្រេច និង បង្គាប់

ចំណុចវិវាទទី១ ៖

- បង្គាប់ឱ្យនិយោជកសងរំលឹកប្រាក់ឈ្នួលឈប់សម្រាកលំហែមាតុភាពចំនួន ៥០ ភាគរយ រយៈពេល ៣ ខែ ជូនកម្មករនិយោជិតស្ត្រីដែលបានឈប់សម្រាកលំហែមាតុភាព។
- បដិសេធពិចារណាលើការទាមទាររបស់ភាគីកម្មករនិយោជិតឱ្យនិយោជកសងរំលឹកប្រាក់បំណាច់មាតុភាព ប.ស.ស. ចំនួន ៧០ ភាគរយ។

ចំណុចវិវាទទី២ ៖

- បដិសេធការទាមទាររបស់ភាគីកម្មករនិយោជិតឱ្យនិយោជកសងប្រាក់រង់ចាំការងារចំនួន ២០ ដុល្លារអាមេរិក សម្រាប់ខែមិថុនា និងខែកក្កដា ឆ្នាំ២០២០ ដែលនិយោជកបានរំសាយពួកគាត់។

ចំណុចវិវាទទី៣ ៖

- បដិសេធពិចារណាការទាមទាររបស់ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកបង់ប្រាក់ភាគទានជូន ប.ស.ស. ឱ្យបានទៀងទាត់ ដើម្បីឱ្យកម្មករនិយោជិតអាចប្រើប្រាស់សេវារបស់ ប.ស.ស.។

ប្រភេទនៃសេចក្តីបង្គាប់ ៖ សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច

សេចក្តីបង្គាប់នេះ នឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ ចំនួន ០៨ ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងរយៈពេលនេះទេ។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក ៖

ឈ្មោះ ៖ **យូ សួនទី**

ហត្ថលេខា ៖ ----------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖

ឈ្មោះ ៖ **អន ណាន**

ហត្ថលេខា ៖----------------------------

ប្រធានក្រុមអាជ្ញាកណ្តាល ៖
ឈ្មោះ ៖ **ម៉េន ម៉ីនឈា**
ហត្ថលេខា ៖ -----------------------------------------